**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៩៧៤

ចុះថ្ងៃទី ២៨-៣-២០០៧

សាលក្រមលេខ ៤៥ " ន"

ចុះថ្ងៃទី ០៨-០៧ -២០០៩

**គាមនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងរាជធានីភ្នំពេញនាថ្ងៃទី**២៤ ខែមិថុនា ឆ្នាំ ២០០៩** ដោយមានសមាសភាពចូលរួមដូចតទៅ :

**ចៅក្រមជំនុំជំរះ**

-លោកស្រី [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ ៩៧៤ ចុះថ្ងៃទី ២៨-៣-២០០៧ ដែលមានជនជាប់ចោទ :**

ឈ្មោះ[redacted]អាយុ៣៨ឆ្នាំ ភេទប្រុស ជាតិខ្មែរ កើតនៅភូមិអណ្តូង ឃុំគោករកា ស្រុកដង្កោ ខេត្តកណ្តាល ទីលំនៅសព្វថ្ងៃភូមិអូរអណ្តូង សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ[redacted] ឪពុកឈ្មោះ[redacted]ស្លាប់ " ម្តាយឈ្មោះ[redacted] ទោសពីមុនគ្មាន ។

ត្រូវចាប់ខ្លួនថ្ងៃទី ១០-១២-២០០៨ ឃុំខ្លួនលេខ ២១៦៦តព្រ ចុះថ្ងៃទី ១៨-១២-២០០៨ ។

ជាប់ចោទពីបទ: **ផ្តល់សក្ខីភាពក្លែង និង ក្លែងលិខិតឯកជន** ប្រព្រឹត្តនៅ ក្រុងភ្នំពេញ កាលពីថ្ងៃទី ០៤ខែតុលា ឆ្នាំ២០០៤.០៧-០៣-១៩៩៣ និង កាលពីថ្ងៃទី ១០-៤-១៩៩៣ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ភេទប្រុស អាយុ៦០ឆ្នាំ ទីលំនៅសព្វថ្ងៃផ្ទះលេខ១៩៦ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ដែលមានលោកមេធាវី[redacted] ជាមេធាវីតំណាង ។

មេធាវីការពារជនជាប់ចោទគឺលោ[redacted]។

**<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ</u> :**

នៅថ្ងៃទី ០៧-០៣-១៩៩៣ ថ្ងៃទី ១០-០៤-១៩៩៣ និងថ្ងៃទី ០៤-១០-២០០៤ ឈ្មោះ[redacted]និងគូកនបានធ្វើកិច្ចសន្យាទិញ និង លក់ដីក្លែងក្លាយ ដោយបានក្លែងស្នាមមេដៃ និង ក្លែងដាក់ឈ្មោះ[redacted]ជាបានលក់ដីនៅភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ មកអោយខ្លួនឈ្មោះ[redacted] រួចយកលិខិតក្លែងនោះ ទៅប្តឹងតុលាការក្រុងភ្នំពេញ ដើម្បីឱ្យតុលាការសំរេចប្រគល់ដីឱ្យខ្លួនធ្វើជាម្ចាស់កម្មសិទ្ធស្របច្បាប់ ។

បានឃើញដីការសន្និដ្ឋានស្ថាពរលេខ៦៦៨អយជ ចុះថ្ងៃទី៣១-៣-២០០៩ របស់តំណាងអយ្យការអមតុលាការដំបូងរាជធានីភ្នំពេញ ។

បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ៧២៧៣ ត-ព្រ ចុះថ្ងៃទី ២១-៥-២០០៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

<u>ពេលសនាទការ</u>

ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា: ខ្ញុំពិតជាបានផ្តល់សក្ខីភាពក្លែងប្រាកដមែន ខ្ញុំមិនស្គាល់ [redacted] ទេ ខ្ញុំបានទទួលលិខិតពីលោក [redacted] ជាអ្នកធ្វើឯកសារ ។ [redacted] មិនបានរកស៊ីជាមួយខ្ញុំបាទទេ ក្រោយពីបានសាលក្រម ហើយខ្ញុំបានពឹងអោយឈ្មោះ [redacted] យកទៅបញ្ជាក់ [redacted] រកស៊ីជាមួយខ្ញុំ កិច្ចសន្យាចុះថ្ងៃទី ០៧-៣-១៩៩៣ និង ១០-៤-១៩៩៣ ខ្ញុំពុំបានផ្តិតមេដៃនៅចំពោះមុខឈ្មោះ [redacted] ទេ ។ ខ្ញុំជាអ្នកយកឯកសារអោយតុលាការ រួចតុលាការកោះហៅអ្នកណាមកសួរខ្ញុំមិនបានអោយគេទៅឆ្លើយទេ ខ្ញុំឈរឈ្មោះទិញដីដោយឈ្មោ [redacted] ( នគរបាលប៉ុស្តិ៍) ជាអ្នកធ្វើឯកសារឱ្យខ្ញុំ ប្រាក់ខ្ញុំយកអោយ [redacted] ហើយ [redacted] អោយអ្នកលក់បន្តទៀត ដោយក្នុងតម្លៃ១ម៉ែ=១ដុល្លា ដីនោះសរុបលុយអស់ជាង ១០ម៉ឺនដុល្លា( ដប់ម៉ឺនដុល្លាអាមេរិច) ឯកសារខ្ញុំជាអ្នកយកផ្តល់អោយតុលាការ ហើយតុលាការសំរេចសេចក្តីអោយខ្ញុំឈ្នះ គោលបំណងដើម្បីទៅធ្វើបណ្ណ័កាន់កាប់ បណ្ណ័ឈ្មោះ [redacted] ខ្ញុំជាអ្នកយកមកដាក់នៅតុលាការជាបណ្ណ័ថតចំលង ឯកសារដើមពុំដឹងនៅទីណាទេ ។

មេធាវីដើមបណ្តឹងឆ្លើយបញ្ជាក់ថា [redacted] មានបុគ្គលពិតប្រាកដ ឯ [redacted] ដែល [redacted] បង្ហាញតុលាការ គឺជាមនុស្សក្លែងក្លាយ ។ [redacted] ពិតប្រាកដក៏បានចូលមកបំភ្លឺតុលាការរួចហើយគឺចម្លើយនៅអយ្យការចុះថ្ងៃទី២៩-៣-២០០៧ ។

មេធាវីតំណាងដើមបណ្តឹង [redacted] សន្និដ្ឋាន :នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៥៧៤ ចុះថ្ងៃទី ២៨-៣-២០០៧ បានបញ្ជាក់ថាជនជាប់ចោទ និង តួកនបានយកឈ្មោះកូនក្តីខ្ញុំបាទទៅធ្វើជាសាក្សីក្នុងរឿងរដ្ឋប្បវេណីលេខ ២២៨ ចុះថ្ងៃទី ០២-០៣-២០០៤ ដោយយកឈ្មោះកូនក្តី [redacted] ធ្វើជាអ្នកលក់ដីអោយឈ្មោ [redacted] តែតាមការពិតកូនក្តីខ្ញុំបាទ ឈ្មោ [redacted] ពិតប្រាកដមិនដែលបានលក់ដីអោយ [redacted] ឡើយ ហើយក៏មិនដែលបានចូលទៅបំភ្លឺនៅតុលាការពីរឿងលក់ដីអោយ [redacted] ដែរ ។ ក្នុងរឿងក្លែងអត្តសញ្ញាណកូនក្តីខ្ញុំបាទឈ្មោ [redacted] នេះ គឺពុំមែនមានតែ [redacted] ម្នាក់ទេគឺមានអ្នករៀបចំឯកសារ និង មានអ្នកផ្តល់ថវិការដើម្បីបានសំរេចនូវគោលបំណងយកដីទៅចាត់ចែងជាកម្មសិទ្ធិ និង លក់បន្តទៀតនោះ ហើយតួកនដែលបានប្រព្រឹត្តជាមួយ [redacted] ចៅក្រមស៊ើបសួរបានលើកលែងចោទប្រកាន់ដោយគ្មានសាវតាជាតិ ប៉ុន្តែតាមពិតតួកនសុទ្ធតែមានសាវតាជាតិទាំងអស់ ដូចនេះខ្ញុំបាទនៅតែទទូចសុំអោយតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និង សុំអោយបង្វិលសំណុំរឿងដើម្បីចោទប្រកាន់លើតួកនតាមច្បាប់ ។

តំណាងអយ្យការសន្និដ្ឋាន: [redacted] ទទួលស្គាល់ថាបានធ្វើកិច្ចសន្យាទិញដី និងកិច្ចសន្យាប្រគល់ប្រាក់ [redacted] ពិត មិនបានចូលរួមក្នុងលិខិតនេះឡើយអំពើរបស់ឈ្មោ [redacted] គឺជាបទល្មើសដូចក្នុងមាត្រា៥០.៥៦នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ឯកាលបរិច្ឆេតឱ្យតុលាការយកថ្ងៃបង្ហាញថ្ងៃពេលសវនាការដូចនេះតំណាងអយ្យការសុំតំកល់ការចោទប្រកាន់ទុកជាបានការដដែល ។

មេធាវីជនជាប់ចោទសន្និដ្ឋានការពារ : ខ្ញុំយល់ថាកូនក្តីខ្ញុំធ្វើតាមគេជាអ្នកធ្វើអោយ ដោយឈ្មោះ [redacted] ជាអ្នកធ្វើឱ្យ តែកូនក្តីខ្ញុំដោយរៀនបានតិចតួចមិតិចពេកក៏មិនបានពិចារណាវែងឆ្ងាយទើបគាត់ធ្វើដូចនេះ សូមលោកស្រីចៅក្រមជំនុំជំរះមេត្តាជួយបន្ធូរបន្ថយទោសឱ្យកូនក្តីខ្ញុំបាទដោយក្តីអនុគ្រោះ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ៧



Scanned by CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីតំណាងដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និង ពិចារណាលើសំណុំរឿងសព្វគ្រប់

## សាលាដំបូងរាជធានីភ្នំពេញ

## យល់ឃើញថា:

-តាមកំណត់ហេតុយកចម្លើយឈ្មោ[redacted]នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ២២៨ ចុះថ្ងៃទី០២-៣-២០០៤ ជាបុគ្គលក្លែងបន្លំដាក់ឈ្មោះ[redacted]គឺចុះថ្ងៃទី២៨-០៤-២០០៤ ដែលកាលបរិច្ឆេទនេះជាពេលវេលាធ្វើអោយតុលាការជឿជាក់ឯការបរិច្ឆេទចុះថ្ងៃទី ០៤-១០-២០០៤ គឺជាពេលវេលាសាលក្រមចូលជាស្ថាពរហើយតំណាងអយ្យការមានការភាន់ច្រឡំលើកាលបរិច្ឆេទនេះ ដូចនេះដើម្បីចោទប្រកាន់ជនជាប់ចោទ អោយត្រូវតាមកាលបរិច្ឆេទនៃការផ្តល់សក្ខីភាពក្លែងក្លាយ តុលាការត្រូវកែប្រែកាលបរិច្ឆេទនៃការចោទប្រកាន់ពីថ្ងៃទី០៤-១០-២០០៤ មកជាថ្ងៃទី២៨-០៤-២០០៤វិញ។

-កាលពីថ្ងៃទី ២៨- ០៤-២០០៤ ,០៧-០៣-១៩៩៣ ,១០-០៤-១៩៩៣ មានអំពើផ្តល់សក្ខីក្លែងក្លាយ និងក្លែងលិខិតឯកជនមួយកើតឡើងនៅក្រុងភ្នំពេញ ដែលអំពើនេះបង្កឡើងដោយលោ[redacted]

-ជនជាប់ចោទបានឱ្យមនុស្សម្នាក់ដាក់ឈ្មោះ[redacted]ដើម្បីមកបំភ្លឺតុលាការក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ២២៨ ចុះថ្ងៃទី០២-០៣-២០០៤ ថាបានលក់ដីស្ថិតនៅក្នុងភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ មកឱ្យខ្លួនហើយដោយសារតែតុលាការជឿលើសាក្សីឈ្មោះនេះ ទើបតុលាការសំរេចប្រគល់ដីនេះអោយឈ្មោ[redacted]តាមសាលក្រមរដ្ឋប្បវេណី ១៤ឈ ចុះថ្ងៃទី១៩-០៥-២០០៤ ប៉ុន្តែឈ្មោ[redacted]នេះគឺជាមនុស្សក្លែងក្លាយ ព្រោះតាមប្រវត្តិរូបបញ្ជាក់ថា ឪពុកម្តាយប្រពន្ធកូនវាខុសពីប្រវត្តិរូប[redacted]ជាដើមបណ្តឹងក្នុងរឿងព្រហ្មទណ្ឌលេខ៥៧៤ ចុះថ្ងៃទី ២៨-០៣-២០០៧ ។

-អំពើរបស់ជនជាប់ចោទ [redacted]គឺជាការបង្ហាញនូវសក្ខីភាពក្លែងក្លាយក្នុងនីតិវិធីតុលាការ ហើយអំពើនេះជាបទធ្វើសក្ខីភាពក្លែងក្លាយ តាមមាត្រា៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-តាមកិច្ចសន្យាទិញ និង លក់ដី ចុះថ្ងៃទី ០៧-០៣-១៩៩៣ និង លិខិតប្រគល់ប្រាក់ផ្តាច់ចុះថ្ងៃទី ១០-០៤-១៩៩៣ បានបង្ហាញថាឈ្មោ[redacted]គឺជាអ្នកលក់ដី និងជាអ្នកទទួលប្រាក់ ប៉ុន្តែការបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] (ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ៥៧៤/២៨-០៣-២០០៧) បញ្ជាក់ថាខ្លួនមិនដែលផ្តិតមេដៃលក់ដី និងទទួលប្រាក់ពីឈ្មោះ[redacted]ឡើយ នេះបញ្ជាក់ថាលិខិតស្នាមដែលឈ្មោ[redacted]ធ្វើឡើងនេះគឺជាឯកសារក្លែងក្លាយទាំងអស់ ។

-លិខិតប្រគល់ប្រាក់ផ្តាច់ចុះថ្ងៃទី ០៧-០៣-១៩៩៣ រវាងឈ្មោ[redacted]និងឈ្មោ[redacted]និងកិច្ចសន្យាទិញនិងលក់ដី ចុះថ្ងៃទី ១០-០៣-១៩៩៣ រវាងអ្នកលក់[redacted] និងអ្នកទិញឈ្មោះ [redacted] គឺជាឯកសារក្លែងក្លាយ វាពុំមានតំលៃគតិយុត្តិឡើយ ។

-អំពើរបស់ជនជាប់ចោទគឺជាការក្លែងឯកសារឯកជនដែលអំពើនេះត្រូវចាត់ជាបទព្រហ្មទណ្ឌតាមមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ៕



Scanned by CamScanner

-តាមចម្លើយរបស់ជនជាប់ចោទថា លិខិតប្រគល់ប្រាក់ចុះថ្ងៃទី១០-០៤-១៩៩៣ និងកិច្ចសន្យាទិញលក់ដី ចុះថ្ងៃទី ១០-០៣-១៩៩៣ រវាងខ្លួន និងឈ្មោ[redacted]ឈ្មោ[redacted]បានប៉ុស្តិ៍នគរបាលជាអ្នករៀបចំអោយ នោះតុលាការពុំអាចជឿបានឡើយ ព្រោះថាពុំមានសាក្សី និងឯកសារបញ្ជាក់ជូនតុលាការឡើយ ម្យ៉ាងខ្លួនជាអ្នកប្រគល់ប្រាក់ថ្លៃដី ហេតុអ្វីមិនអោយអ្នកលក់ដីមកផ្តិតមេដៃទទួលប្រាក់ចំពោះមុខខ្លួននោះ ចំឡើយនេះពុំមានលក្ខណៈសមស្របអាចអោយតុលាការជឿបានទេ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់បញ្ជាក់ថាជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស អាយុ ៣៨ឆ្នាំ ពិតជាបានប្រព្រឹត្ត អំពើផ្តល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជនទៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២៨-៤-២០០៤ .១៩-៥-២០០៤.១០-៣-១៩៩៣ .១០-៤-១៩៩៣ ប្រាកដមែន ។

-លោកមេធាវី[redacted]ជាមេធាវីតំណាងអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]បានប្តឹងសុំទាមទារថ្លៃខូចខាត និង ជំងឺចិត្តចំនួន ៥០.០០០ដុល្លារ( ប្រាំម៉ឺនដុល្លារអាមេរិច) មានលក្ខណៈសមស្របគប្បីតុលាការពិនិត្យ និងសំរេចតាមភាពជាក់ស្តែង ។

-ដើម្បីចៀសវាងការឃុំខ្លួនហួសនីតិវិធី តុលាការគប្បីផ្តន្ទាទោសជនជាប់ចោទនាពេលនេះ ឯត្លុកនតុលាការគប្បីបង្វិលសំណុំរឿងជូនលោកព្រះរាជអាជ្ញាវិញ ដើម្បីធ្វើការចោទប្រកាន់ និងចាត់ការតាមនីតិវិធីជាបន្តទៀត ។

-តាមការផ្តល់ភស្តុតាង និងការអះអាងរបស់មេធាវីតំណាងដើមបណ្តឹងបញ្ជាក់ថា ត្លុកនមានសវតាច្បាស់លាស់ ហើយត្លុកននេះជាអ្នករៀបចំឯកសារក្លែង ហើយជាអ្នកផ្តល់ឯកសារបណ្ណកម្មសិទ្ធិថតចំលងផងដែរ ដែលការអះអាងនេះអាចអោយតុលាការជឿបាន ព្រោះថាជនជាប់ចោទពុំបានឆ្លើយបញ្ជាក់ជូនតុលាការនាពេលសវនាការថាអ្នកណោជាអ្នកផ្តល់បណ្ណកម្មសិទ្ធិអោយមកខ្លួនបានឡើយ ដែលនេះសបញ្ជាក់ថាអ្នកផ្តល់បណ្ណកម្មសិទ្ធិដើម្បីអោយតុលាការសំរេចបដិសេធនោះគឺជាត្លុកន ហើយត្លុកននេះតំណាងអយ្យការនៅពុំទាន់បានធ្វើការចោទប្រកាន់ និងបញ្ជូនមកតុលាការជំនុំជំរះឡើយ ដូចនេះដើម្បីកុំអោយជនប្រព្រឹត្តបទល្មើសរួចផុតពីការផ្តន្ទាទោស តុលាការគប្បីបង្វិលសំណុំរឿងទៅអយ្យការវិញ ដើម្បីធ្វើការចោទប្រកាន់លើត្លុកន និង ចាត់ការតាមនីតិវិធីជាបន្តទៀត ។

<u>ហេតុដូច្នេះសាលាដំបូងរាជធានីភ្នំពេញ</u>

<u>វិនិច្ឆ័យសេចក្តី</u>

១-ផ្តន្ទាទោសឈ្មោះ[redacted]ភេទប្រុស អាយុ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០៤ឆ្នាំ "បួនឆ្នាំ" គិតបន្តពីសាលក្រមមុន និង ពិន័យជាប្រាក់ចំនួន ៤.០០០.០០០រៀល( បួនលានរៀល) សំរាប់ដាក់ចូលក្នុងថវិការដ្ឋ ពីបទៈផ្តល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២៨-០៤-២០០៤ .១៩-០៥-២០០៤ .០៧-០៣-១៩៩៣ .១០-០៤-១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥៦ .៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-បង្គាប់អោយឈ្មោ[redacted]ងថ្លៃខូចខាត និង ជំងឺចិត្តចំនួន ៤០.០០០.០០០រៀល( សែសិបលានរៀល) អោយទៅឈ្មោ[redacted]បមានលោក[redacted]ជាមេធាវីតំណាង ។ ការសុំលើសពីនេះត្រូវច្រានចោល ។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៩៧៤ ចុះថ្ងៃទី២៨-០៣-២០០៧ ជូនលោកព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញវិញ ដើម្បីបើកការស៊ើបសួរលើត្លុកន និង ចាត់ការតាមនីតិវិធី ។/៚



Scanned by CamScanner

៤-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី២៤-០៦-២០០៩ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ០៨-០៧-២០០៩ ចំពោះមុខ ជនជាប់ចោទ **សុខ ឃិន** មេធាវីការពារជនជាប់ចោទ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។៚

| ក្រឡាបញ្ជីសវនាការ | ចៅក្រមជំនុំជំរះ |
| --- | --- |
| ហត្ថលេខា និង ត្រា [redacted] | ហត្ថលេខា និង ត្រា [redacted] |

ចៅក្រមជំនុំជំរះ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៩

ក្រឡាបញ្ជី

[redacted]

[redacted]